ត្រូវការជំនួយខាងច្បាប់?

សូមទូរស័ព្ទមក <u>ផាញ ទ្រី លីគាល់ អាស៊ីស្ទែន</u>

ជំនួយឥតគិតថ្លៃ សម្រាប់អ្នកមានប្រាក់ខែតិច នៅរដ្ឋម៉ែន

## ជំនួយច្បាប់ ដោយឥតគិតថ្លៃ សម្រាប់អ្នកមានប្រាក់ខែតិច

<u>ផាញ ទ្រី លីគាល់ អាស៊ីស្ទែន</u> ជួយលោកអ្នកដោយឥតគិតថ្លៃ ចំពោះអ្នកដែលមានប្រាក់ខែបន្តិចបន្តួច ហើយរស់នៅក្នុងរដ្ឋម៉ែន។ ការបម្រើរបស់យើង ពុំមានគិតថ្លៃឈ្នួលឡើយ។ យើងប្រហែលជាអាចជួយលោកអ្នកបាន បើៈ ប្រាក់បៀវត្សរបស់អ្នកស្មើនិងឬក៏តិចជាង១២៥ភាគរយ នៃភាពក្រីក្ររបស់រដ្ឋាភិបាល អាមេរិកាំង ឬក៏ លោកអ្នកជាជនរងគ្រោះការវិវាទក្នុងគ្រួសារ។

យើងសូមអភ័យទោស បើយើងពុំអាចជួយអ្នក ដែលទទួលសំបុត្រខុសច្បាប់ចរាចរ() និងអ្នកជាប់ទោសថ្នាក់មជ្ឈិម។ ដោយហេតុថា យើងមានបុគ្គលិកធ្វើការតិចពេក, យើងមិនអាចជួយអ្នកគ្រប់ៗគ្នាបានទេ។ សូមទាក់ទងការិយាល័យ <u>ផាញ ទ្រី លីគាល់ អាស៊ីស្ទែន</u> ដែលមានទីតាំងជិតអ្នក ក្រែងយើងអាចជួយអ្នកបាន។

បើសិនណាជាអ្នក មិនចេះនិយាយភាសាអង់គ្លេស អ្នកអាចទាក់ទងយើង ដោយហៅលេខ ៧៧៤-៨២១១ លេខបន្ត ២, ពេលនោះ អ្នកត្រូវទុកដំណឹងទាក់ទងគ្នាមកយើង ៗនឹងទាក់ទងទៅលោកអ្នកវិញ។ នេះហាក់បីដូចជា មិនជាការស្និតស្នាលប៉ុន្មានទេ ប៉ុន្តែវា អាចជួយយើងបំពេញសេចក្តីត្រូវការរបស់អ្នកបាន។ សូមទុកមធ្យោបាយទាក់ទងនេះឲ្យយើង យើងនឹងទូរស័ព្ទទៅអ្នកវិញ។ តាមធម្មតា ទូរស័ព្ទយើងតែងតែរវល់ណាស់, ពេលខ្លះអ្នកមានការពិបាកទូរស័ព្ទចូលមកយើង តែយើងក៏ចង់ជួបអ្នកផ្ទាល់ដែរ ដូច្នេះ សូមព្យាយាមទូរស័ព្ទមកយើងទៀត កុំរួញរាឡើយ។ លេខទូរស័ព្ទ តែងតែរវល់ណាស់នៅថ្ងៃចន្ទនិងថ្ងៃសុក្រនិងពេលព្រឹក។ ដូច្នេះ សូមទូរស័ព្ទមកវិញ នៅពេលផ្សេងពីខាងលើនេះ។

សូមកុំរង់ចាំដល់ពេលប្រចុចញ្ជៀច ទើបទាក់ទងមក យើង ហើយចាត់ទុកការនេះជាភាពអាសន្នទៅវិញនោះ។

តើមានរបៀបធ្វើយ៉ាងណា ក្រោយពីពេល ដែលអ្នកបានដាក់ពាក្យសុំជំនួយច្បាប់ហើយ អំពី <u>ផាញ ទ្រី លីគាល់ អាស៊ីស្តែន?</u>

សូមទូរស័ព្ទលេខ ៧៧៤-៨២១១ លេខបន្ថែម ២ ឬក៏អញ្ជើញទៅកាន់ការិយាល័យ <u>ផាញ ទ្រី លីគាល់</u> ដែលមានទីតាំងនៅជិតលោកអ្នក។ បើសិនជា អ្នកមិនចេះភាសាអង់គ្លេស ត្រូវធ្វើសំណូមពរសុំអ្នកប្រែភាសាពេលនេះតែម្តង។ យើងនឹងជួយផ្តល់អ្នកដោយឥតគិតថ្លៃ។ ដើម្បីឲ្យដឹងថា អ្នកមានលទ្ធភាពទទួលជំនួយផ្លូវច្បាប់អំពីយើងឬយ៉ាងណានោះ យើងសូមសួរអ្នកខ្លះៗ អំពីប្រាក់ខែ និងដំណឹងអំពីបញ្ហាផ្ទាល់ខ្លួន។ <u>ផាញ ទ្រី លីគាល់ អាស៊ីស្តែន</u> និងមិនបញ្ចេញដំណឹងនេះ ទៅអ្នកណាឡើយ លើកលែងតែមានការអនុញ្ញាតិអំពីអ្នកជាមុន។ បើលោកអ្នក មិនមានលទ្ធភាព ទទួលជំនួយផ្លូវច្បាប់របស់យើងបាននោះ យើងនិងជម្រាបលោកអ្នកនៅពេលនោះ ភ្លាម។ បើលោកអ្នកលទ្ធភាពទទួលជំនួយ យើងនឹងជួយ:

របៀបដោះស្រាយ នូវបញ្ហារបស់លោកអ្នក ដោយខ្លួនឯង។ យើងនឹងជូនលោកអ្នកផងដែរ នូវដំណឹងស្តីអំពីសិទ្ធិផ្លូវច្បាប់របស់អ្នក។ យើងប្រហែលជាត្រូវការដំណឹងបន្ថែមអំពីករណីរបស់លោកអ្នក។ យើងនឹងសើរើពិនិត្យ មុននឹងយើងជួបអ្នកជាថ្មីម្តង ទៀត ដើម្បីជម្រាបអំពីមធ្យោបាយដោះស្រាយ។ យើងប្រហែលជាត្រូវការ ធ្វើការ សាវជ្រាវខាងច្បាប់ខ្លះៗ ហើយនិងពិភាក្សាអំពីករណីរបស់អ្នក មុននឹងយើងអាច ផ្តល់ជំនួយច្បាប់ ដោះស្រាយដោយវិធីណាមួយ នៅពេលជួបគ្នានាថ្ងៃបន្ទាប់។ សូមបញ្ជាក់ថា លោកអ្នកត្រូវតែយល់ អំពីសេវាកម្មរបស់យើងឲ្យបានច្បាស់លាស់ បើមិនយល់ត្រូវសួរ។

សូមកត់ត្រាឈ្មោះ អ្នកណាដែលកំពុងកាន់បញ្ជីករណីរបស់អ្នក។

ធ្វើកំណត់ហេតុ ដោយខ្លួនឯង។
បើលោកអ្នកត្រូវការជំនួយបន្ថែម សូមទាក់ទងមកយើងជាថ្មីទៀត។
យើងនឹងមិនបដិសេធ សេវាកម្មរបស់យើងដោយផ្អែកលើៈ សញ្ញាតិកំណើត, ពណ៌សម្បុរ, ការនិយមភេទ, ទស្សនិយម, អាយុ, ជំនឿសាសនា, និន្នាការនយោបាយឬជំនឿ, ភាពពិការ។

យើងប្រហែលជាអាចជួយផ្លូវច្បាប់ ទៅលើករណីដូចខាងក្រោមនេះ:

ការដេញមនុស្សចេញពីផ្ទះឈ្នួល, បញ្ហារវាងម្ចាស់ផ្ទះនិងអ្នកជួល និង បញ្ហាផ្ទះដែលពុំមានសន្តិសុខ និង បញ្ហាទទួលប្រាក់វិលហ្វា(រួមមាន ប្រាក់ថែនទីហ្វ-ហ្វតស្តែម ជំនួយទូទៅ, ភាពពិការ ការអស់ការងារធ្វើ)
ការវិវាទក្នុងផ្ទះ
សេវាកម្មនិងការធានាសុខភាពរបស់មេឌីខេតនិងសិទ្ធិប្រើប្រាស់មន្ទីរព្យាបាល
ការជួយបន្ថយពន្ធផ្ទះ ចំពោះម្ចាស់ផ្ទះ ដែលមានប្រាក់ខែតិច
ការសិក្សា តាមកម្មវិធីអប់រំ/សិក្សាពិសេស
បញ្ហាទិញដូររបស់របរ
បញ្ហាជាមួយនឹងកម្មវិធីជំនួយមនុស្សធំមនិងប្រាក់សងកូន
ការហ្វិកហ្វឺនការងារ(អាស-ស្មៀយ និង ផាស)
បញ្ហាច្បាស់ស៊ីវិលទូទៅ

សូមអភ័យទោស ដែលយើងមិនទទួលករណីទោសមជ្ឈិមឬក៏ការល្មើសច្បាប់ចរាចរ។
បើលោកអ្នកត្រូវកាជំនួយច្បាប់គ្រួសារ(ការលែងលះប្តីប្រពន្ធ, ការទាមទារចំណែកកូន សូមទាក់ទងលេខ ១-៨០០-៤៤២-៤២៩៣ឬ៧៧៤-៤៣៦៨។

តើលោកអ្នកអាចទាក់ទងយើងនៅកន្លែងណា?

ការិយាល័យរបស់យើង បើកទ្វារពីថ្ងៃច័ន្ទទៅថ្ងៃសុក្រ ផ្តើមពីម៉ោង ៨:៣០ ព្រឹក ទៅម៉ោង ១២ ថ្ងៃត្រង់ នៅតាមទីកន្លែងដូចខាងក្រោមៈ

លេខ ៣៧៣ វិថីម៉េន
ក្រុងប្រេស្តាយ, ម៉ែន

លេខ ៣៩ វិថីគ្រីន
អៅហ្គាស្តា, ម៉ែន

លេខ ៦១ វិថីម៉េន
ក្រុងបែងហ្គោ, ម៉ែន

លេខ ៨៨ វិថីហ៊្វដើរិល
ផតខ្លែន, ម៉ែន

ការិយាល័យទាក់ទងសាធារណៈ(សូមមើលពេលម៉ោងបើកទ្វារ)

លេខ ១៤៥ វិថីលីស្បូន
ក្រុងល្វីស្តុន , ម៉ែន

លេខ ១ វិថីស្គូល
ក្រុងម៉ាជាស, ម៉ែន

ក្រុមឯកភាពសញ្ជាតិអាមេរិកាំង-ម៉ិនខៀននិងក្រុមកសិករ
លេខ ៣៧៣ វិថីម៉េន
ក្រុងបែងហ្គោ, ម៉ែន

សូមបើកគេហទំព័រវិបសៃរបស់យើង(www.://ptla.org)
ដែលមានពត៌មានឥតគិតថ្លៃជាច្រើន ដែលស្តីអំពី សិទ្ធិប្រើប្រាស់ច្បាប់របស់អ្នក និងបានជាពន្លឺសម្រាប់ដោះស្រាយបញ្ហា ដោយខ្លួនឯង។
លោកអ្នកអាចប្រើអ៊ិនធើណិតបាន នៅតាមពបណ្ណាគារសៀវភៅនិងសាលារៀន។